IB DIPLOMA PROGRAMME
PROGRAMME DU DIPLÔME DU BI
PROGRAMA DEL DIPLOMA DEL BI

22070535

**KHMER A1 – STANDARD LEVEL – PAPER 1**
**KHMER A1 – NIVEAU MOYEN – ÉPREUVE 1**
**KHMER A1 – NIVEL MEDIO – PRUEBA 1**

Monday 14 May 2007 (morning)
Lundi 14 mai 2007 (matin)
Lunes 14 de mayo de 2007 (mañana)

1 hour 30 minutes / 1 heure 30 minutes / 1 hora 30 minutos

---

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Write a commentary on one passage only. It is not compulsory for you to respond directly to the guiding questions provided. However, you may use them if you wish.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez un commentaire sur un seul des passages. Le commentaire ne doit pas nécessairement répondre aux questions d'orientation fournies. Vous pouvez toutefois les utiliser si vous le désirez.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario sobre un solo fragmento. No es obligatorio responder directamente a las preguntas que se ofrecen a modo de guía. Sin embargo, puede usarlas si lo desea.



© IBO 2007

*សូមអ្នកសរសេរអត្ថាធិប្បាយទៅលើអត្ថបទតែមួយ ក្នុងចំណោមអត្ថបទទាំងពីរខាងក្រោមនេះ*

**១ (ក)** ព្រលឹងជាតិយំ

ឥឡូវយើងនៅចំស្រុកសម្បូណ៌
អស់ឮពាក្យថ្ងូរថាឃ្លានថាអត់
ពេលបានជួបគ្នានឹកគ្រាកំសត់
នឹកការជូរចត់ប្រិចគេធ្វើបាប ។

ឆ្នាំចិតសិបប្រាំរំដោះភ្នំពេញ
រាស្ត្រប្រិចគេដេញរត់ចេញខ្ចាត់ខ្ចាយ
បងខ្លះបែកប្អូនកូនខ្លះបែកម្តាយ
ខ្លះដប់ឆ្នាំឆ្ងាយពុំទាន់ជួបគ្នា ។

ដើរផងរត់ផងភ្នែកមើលឆ្លាឆ្លាប់
ត្រចៀកផ្ទៀងស្តាប់ក្រែងឮមាត់ហៅ
អ្នកក្រុងរាប់សែនប្រិចកេណ្ឌចេញទៅ
យាយខ្លះបែកចៅយំឮហ៊ូរៗ ។

ចូលដល់ស្រុកស្រែខ្លួនប្រែកំសត់
ជួនហូបជួនអត់ព្រោះអីខ្វះស្បៀង
ធ្វើការនឿយហត់ស្រេចតែគេកៀង
ខ្លះបីខែជាងគ្មានស្គាល់មុខងារ ។

អ្នកធ្លាប់ធ្វើស្មៀនធ្លាក់ទៅធ្វើស្រែ
អ្នកធ្វើចៅកែប្រែទៅភ្ជួរដី
អ្នកឥតបានរៀនធ្វើស្មៀនធ្វើថី
អ្នកប្រៀងល្បីៗឱ្យទៅដាំចេក ។

ខ្ទង់បីលាននាក់បញ្ជាក់ថាខ្មែរ
បានដេកចាំស្រែនិងចាំរណ្ដៅ
អធ្រាត្រយប់ស្ងាត់ព្រលឹងចេញហៅ
ប្រមូលកូនចៅរើសធាតុធ្វើបុណ្យ ។

ព្រលឹងជាតិខ្មែរយំក្បែរមាត់បឹង
មើលផ្លូវទន្ទឹងកូនចៅគ្រប់ប្រាណ
បង្អួកស្រែកហៅញាតិផៅសន្តាន
ត្រូវវិលភូមិឋានកសាងប្រទេស ។

ផ្លូវឡានតូចៗត្រូវពង្រីកធំ
ធ្វើស្ពានឱ្យមាំសមនឹងផ្លូវថ្មី
ដឹកនាំកូនចៅទាំងប្រុសទាំងស្រី
កសាងទឹកដីឱ្យបានជឿនលឿន ។

អ្នកនិពន្ធ គីមហួយទ្រុង
រៀបរៀងដោយ ជក ឈី ហ្កាស
សំណោកស្រុកខ្មែរ
បោះពុម្ពឆ្នាំ ១៩៩១

– តើកំណាព្យនេះ អ្នកនិពន្ធចង់និយាយពីគំនិតអ្វីដែលសំខាន់ ?

– តើភាសាដែលប្រើដោយអ្នកនិពន្ធជួយបង្កើតរូបភាពក្នុងអារម្មណ៍អ្នក ស្ដីពីការស្លាប់និងភាពខ្លាចរន្ធត់ នៅក្នុងកំណាព្យនេះ យ៉ាងដូចម្ដេច ?

– តើអ្នកនិពន្ធប្រើសំលេង " ព្រលឹងជាតិ " បានល្អយ៉ាងដូចម្ដេច ក្នុងការបង្ហាញនូវគំនិតសំខាន់របស់ខ្លួន ?

– តើអ្នកនិពន្ធប្រើរបៀបបច្ចេកទេសបែបណាក្នុងការសរសេរកំណាព្យនេះ ?

**១(ខ)** លោក **ហ្លួង** សួរយ៉ាងសស្លើតសស្លក់ថា "កើតអ្វីហ៎ះ ចៅ **ចិត្រ** ?" ចៅ **ចិត្រ** ចង្អុលទៅពន្លឺដែលកំពុងតែចូលជិតមក១ គ្រប់ ១ ខណៈ ហើយថា "ទានប្រោស ! សូមពិនិត្យមើលគប់ភ្លើងនុ៎ះ មិនទាន់ដឹងជាអ្វីទេ !"

"ប្រហែលជាពួកចោរទេដឹង? លោក **បាឡាត់** និយាយឡើងមុនគេ។

" ប្រហែលជាពួកចោរមែន! ចៅ **ចិត្រ** ថាផ្ទួន ។ កាលចៅ **ចិត្រ** និយាយដូច្នេះហើយ **ហ្លួងរតនសម្បត្តិ** និង លោក **បាឡាត់** ក៏នាំគ្នារត់ទៅរថយន្ត រកបានដែករវៃរថយន្តមួយម្នាក់សម្រាប់ប្រើជាអាវុធបង្ការខ្លួន ។

ឯនាង **នារី** ញ័រខ្លួនចំប្រប់ដូចកូនសត្វ ឈរនៅក្បែរ ចៅ **ចិត្រ** ១ ចាប់ដៃនាងជាប់ ហើយប្រាប់ថា "**យុន** កុំតក់ស្លុតឱ្យសោះ ធ្វើចិត្តឱ្យក្លាហានឡើង, **យុន** ភ្លេចពាក្យដែលខ្ញុំបាទបានសន្យានឹង **យុន** ហើយឬ? "

នាងមិនតបដូចម្តេចឡើយ គ្រាន់តែចាប់ដៃជាប់ដោយភ័យស្លន់ ចៅ **ចិត្រ** ប្រុងខ្លួនយ៉ាងអង់អាច រង់ចាំពេលវេលាដែលមិនទាន់ដឹងជាមានហេតុភេទដូចម្តេចកើតឡើងនៅ ខណៈ នោះទេ ។

នៅទីបំផុតស្រាប់តែឮសំលេងស្រែក ហ៊ោកងរំពងនាកណ្តាលព្រៃស្ងាត់ នាំឱ្យដឹងថា ពួកចោរនោះ មានចំនួនច្រើននាក់ ហើយឮស្នូរកាំភ្លើងច្រើនណាត់ បាញ់តម្រង់មក មានគ្រាប់កាំភ្លើងខ្លះធ្លាក់នៅខាងមុខ ចៅ **ចិត្រ** ក៏មាន ។

អ្នកទាំងពីរ គឺ លោក **ហ្លួងរតនសម្បត្តិ** និង លោក **បាឡាត់** ថយក្រោយទៅយករថយន្តជាគ្រឿងកំបាំង អន្តរាយ **ហ្លួងរតនសម្បត្តិ** ទុកជាចាស់ហើយក៏ពិតមែន តែនៅមានស្មារតីរហ័សរាងវៃណាស់សមជាបុរស ។ ឯ លោក **បាឡាត់** សស្លើតសស្លក់ខំលូនចូលទៅនៅខាងក្រោមរថយន្ត ឯនាង **នារី** មិនព្រមឃ្លាតឆ្ងាយពី ចៅ **ចិត្រ** ឡើយ នៅតែចាប់ដៃជាប់ស្អិត ក្នុងខណៈ នោះ ចៅ **ចិត្រ**អែបបំបាំងខ្លួននឹងដើមស្រឡៅធំ១ដើម ។

ស្នូរសំឡេងហ៊ោគឹកកងរំពងនោះកាន់តែជិតមក ១ ចៅ **ចិត្រ** ខាំ ធ្មេញយ៉ាងណែន ផ្គងកាំភ្លើង ប្រុងស្មារតីយ៉ាងអង់អាច ត្រៀមខ្លួនចាំតទល់នឹងសត្រូវ ដើម្បីការពារស្រីជាទីស្រឡាញ់ពេញចិត្តរបស់ខ្លួន ជីវិត ខ្លួននិងអ្នកទាំងអស់គ្នា ។

ពួកមហាចោរ ក៏បាញ់កាំភ្លើងគ្រាប់ប្រាយមកបាចសាចដូចជាគ្រាប់ភ្លៀង តែឥតត្រូវរាងកាយនរណា មួយឡើយ ព្រោះទីនោះជាទីងងឹតឈ្លុបចាក់ភ្នែកពុំយល់ ចំណែកខាងពួកចោរមានគប់ភ្លើងភ្លឺសន្ធោសន្ធៅពេញទាំងព្រៃ ដូច្នេះបានជាគ្រាប់កាំភ្លើងដែល ចៅ **ចិត្រ** បាញ់ទៅគ្មានខុសមួយគ្រាប់ ចោរខ្លះបាក់ដៃ, ខ្លះបាក់ជើង , ខ្លះដួលចង្រ្កាងទៅក៏មាន ...

ចៅ **ចិត្រ**ខំតស៊ូយ៉ាងក្លាហាន ដើម្បីការពារជីវិតខ្លួន និងជីវិតស្ត្រីសំឡាញ់របស់ខ្លួនដោយអង់អាច ឥតខ្លាចស្លាប់បន្តិចឡើយ ។ ........

...............

**បាឡាត់** "**យុន**មិនស្រឡាញ់ខ្ញុំ ព្រោះ**យុន**មានមនុស្សដែល**យុន**ស្រឡាញ់រួចទៅហើយមែនឬទេ !" និយាយសើចដោយកិរិយាចំអកចំទយ ។ ........

**នារី** "នរណាហ៊ឹះ !" (នាងសួរទាំងខឹង) ។

**បាឡាត់** "គឺ ចៅ **ចិត្រ** នោះឯង, មែន ,ចៅ **ចិត្រ** វាជាក្មេងកំឡោះរូបស្រស់សំដីផ្អែម តែវាទីទ័លក្រ ដូចមនុស្សសូមទានគេមែនទេ !" (ថាហើយក៏សើចក្អាកក្អាយ) ។

**នារី** "លោកអួតខ្លួនវិសេស យ៉ាងណា បានជាហ៊ាននិយាយសង្កត់សង្កិនបន្តុះបង្អាប់គេយ៉ាងនេះ បើទុកជាគេទីទ័លក្រ ក៏ទីទ័លក្រតែទ្រព្យសម្បត្តិប្រាក់មាស តែគុណសម្បត្តិសុខភាពរៀបរយជាសុភាពបុរសជាកូនប្រុសមែន១ នោះ ចៅ **ចិត្រ**មាន

សព្វគ្រប់, ឯខ្លួនលោកមានតែប្រាក់មាសមែនហើយ, លោកអាចទិញដូររបស់អ្វីបានតាមត្រូវការ តែលោកមិនអាចយកប្រាក់មាសរបស់លោកមកទិញសេចក្តីស្នេហារបស់ខ្ញុំបានទេ លោកមានប្រាក់មាសដែលចៅ **ចិត្រ**គ្មាន តែរបស់ដែលចៅ **ចិត្រ**មានលោកមិនមានសោះឡើយ មែនឬទេ!"

**បាឡាត់** "ចុះខ្ញុំមិនមានអ្វី ? នៅខ្វះអ្វីទៀត ?"

**នារី** "សុភាពបុរសនឹងភារៈជាកូនប្រុស " ។

**បាឡាត់** "ក៏នេះមិនមែនកូនប្រុសទេឬ ?"

នាង **នារី**សើចចំអកឱ្យហើយថា "ត្រូវហើយ, តែលោកបាឡាត់គ្រាន់តែមានរាងកាយជាកូនប្រុស, តែចិត្តរបស់លោកខ្លាចលើសស្រីទៅទៀត មែនទេ? ។

អ្នកនិពន្ធ ញ៉ុកថែម
ដកស្រង់ពី រឿង កុលាបប៉ៃលិន
បោះពុម្ពលើកទីមួយ ឆ្នាំ ១៩៤៣

– តើការប្រើភាសា ( រូបភាពក្នុងអារម្មណ៍ ការជ្រើសរើសពាក្យ ជាដើម) ជួយបង្ហាញនូវភាពប្រាកដនិយម នៅក្នុងរឿងនេះយ៉ាងដូចម្តេច?
– តើ ចៅចិត្រ មានសីលធម៌ខ្ពស់ជាង លោកបាឡាត់ បែបណា ?
– តើអ្នកនិពន្ធប្រើបច្ចេកទេសសរសេរបែបណា ក្នុងការសរសេររឿងនេះ ?
– តើអ្នកនិពន្ធចង់អោយអ្នកអានបានដឹងពីគំនិតសំខាន់អ្វី ?